# ទាយខែប្រចាំឆ្នាំទាំង១២

បណ្ដាមនុស្សយើងទូទៅទាំងប្រុស-ស្រី សុទ្ធតែមានទំនាយជាលក្ខណៈផ្សេងៗ ដូចគ្នាខ្លះ ផ្សេងគ្នាខ្លះ កំណើតមនុស្សដែលមានការគួរឱ្យសង្កេតបានទៅដោយលទ្ធភាពសម្រាប់ខ្លួន គប្បីពិនិត្យកំណើតឆ្នាំប្រកាន់ខែនីមួយៗ ទើបបានឃើញច្បាស់នូវលទ្ធភាពរបស់ខ្លួនយ៉ាងប្រត្យក្ស ។

## ១-មនុស្សកើតឆ្នាំជូត

ខែ មេសា ឧសភា និង មិថុនា

ច្រើនបានជាមនុស្សមានសំណាងខ្ពស់ ធ្វើរាជការបានបុណ្យសក្តិ តែអវីះអំណាច ពាក្យសម្ដីថ្លៃថ្នូរ រើសអើងគ្រឿង បរិភោគ ប្រកបការអាជីវកម្មទូទៅបានជាមធ្យម មានគេគោរពរាប់អានស្រឡាញ់គ្រប់វណ្ណៈ តែច្រើនរោគឈឺមាត់ ។

ខែ កក្កដា សីហា និង កញ្ញា

ច្រើនមានទឹកសំដីសាបឡាប និយាយល្អបានផលអាក្រក់ បរិវាររុកកួន ពុំនោះសោតនិយាយចេញពីមាត់ទៅកាន់ គេ គេអឺអើរតែនៅចំពោះមុខ កំបាំងមុខគេមិនយកត្រចៀកត្រងត្រាប់ឬធ្វើតាមឡើយ ចិត្តជាល្អប្រកបទៅដោយសទ្ធា ពេញអធ្យាស្រ័យទៅខាងបុណ្យកុសលសព្វប្រការ ។

ខែ តុលា វិច្ឆិកា ធ្នូ

ច្រើនទទួលបានសេចក្ដីនឿយព្រួយលំបាក ក្នុងការស្វែងរកលាភផលបំរុងជីព រមែងជួបប្រទះនិងការស្រេកឃ្លាន ហួសហេតុរឿយៗ បានទុកលំបាកជាញឹកញយ ព្រោះការធ្វើដំណើរឆ្ងាយ ចិត្តឆាប់ក្រេវក្រោធ ហានក្លា ខឹងហើយចងគំនុំ ទុកបានយូរអង្វែង សម្ដីច្រើនទ្រគោះ ។

ខែ មករា កុម្ភៈ និង មីនា

មានបរិវារច្រើន អាជីពប្រព្រឹត្តទៅដោយសមគួរ មានបុត្រធីតាច្រើននាក់ អធ្យាស្រ័យស្របស្រួលល្អមិត្ត ឬញាតិ ត្រេកអរក្នុងកិច្ចការជាកុសល មានចិត្តអត់ធន់ចំពោះឧបសគ្គ តស៊ូក្នុងការងារ មិនរំភើប ។

## ២-មនុស្សកើតឆ្នាំឆ្លូវ

ខែ មេសា ឧសភា និង មិថុនា

ជាមនុស្សឡើងចាង ដើរលេងច្រើន មិនសូវស្រឡាញ់ការងារ កាលពីតូចឃើញឬកពារស្រួលល្អ មានពូជការប្រឡាយកាត់មិនសូវបរិសុទ្ធ ចិត្តស្រាលហើយខ្លាំង បញ្ហាមិនយកតាមច្រើនឆ្លើយតប ធ្វើការច្រើនខ្ជីខ្ជាបោកបោះ ។

ខែ កក្កដា សីហា និង កញ្ញា

ពាក្យសម្ដីច្រើនរមាំងរម៉ោក រោយរាយ និយាយការអ្វីណាស់ច្រឡំដដែលៗ មានចិត្តមានៈប្រកាន់មុខការ ហើយរឹងរូះយកតាមតែទំនើងខ្លួន គំនិតច្រើនអាងលើគេ ឬ សង្ឃឹមផ្អែកទៅលើការដែលគ្រាន់តែគិតផ្គួរផ្គងបំរុងនឹងប្រកប ច្រើនតាំងចិត្តប្រចាំ ។

ខែ តុលា វិច្ឆិកា និង ធ្នូ

ជាមនុស្សមិនសូវបានសំបូរសប្បាយទៅដោយគ្រឿងបរិភោគ និងឧបភោគប៉ុន្មានឡើយ រាងកាយច្រើនមានការជល់ប៉ះទង្គិចបណ្តាលឱ្យគ្រាំគ្រាពិការរឿយៗ ឬថាច្រើនក្លាយជាបូសបមកមង់ដំបៅនៅលើរាងកាយផ្សេងៗ តែមានអធ្យា ស្រ័យចេះសន្តោសយល់យោគល្អ ទឹកចិត្តស្រឡាញ់ប្តូរផ្តាច់ក្នុងការកុសល ជាមនុស្សដឹងគុណ ។

ខែ មករា កុម្ភៈ និង មីនា

ជាមនុស្សឧត្តមជាតិ សំបូរធនទ្រព្យ មានបរិវារច្រើន មានសេចក្តីសុខចំរើនបរិបូរ តែទឹកចិត្តធ្ងន់ទៅខាងផ្លូវលោភ លន់និងកំណាញ់ស្វិត មិនសូវបានត្រូវជើង ត្រូវដៃ និងអ្នកនៅជិតខាងគ្នាទេ ច្រើនឆ្មើងឆ្មៃឬកវាយសំនួនលើកកំពស់ ប្រ កាន់វណ្ណៈ ។

## ៣-មនុស្សកើតឆ្នាំខាល

ខែ មេសា ឧសភា និង មិថុនា

មានវិជ្ជាខាងសិល្បីសាស្ត្រប្រសិទ្ធភាពល្អ សន្តានចិត្តទាត់ទ្បេត មានសច្ចៈដុះដាលនៅក្នុងអធ្យាស្រ័យជានិច្ច មិនសូវលោភលន់ពេកទេ អបអរសាទរតែក្នុងរបស់ដែលគប្បីមាន គប្បីបាន ប្រសិនបើតាំងខ្លួននឹងចិត្តឱ្យស្ថិតនៅក្នុងវង់ការជាអ្នកវេទមន្ត សិល្បី វិជ្ជា មានពេលខ្លះហាក់ដូចជាមាត់ទិព្វ តែច្រើនក្រទាល់សម្បត្តិភ័ស្សស្ថាន ។

ខែ កក្កដា សីហា និង កញ្ញា

ខ្លួនមានវាសនាតិច ត្រូវប្រកបកិច្ចការបម្រុងអាជីពដោយការធ្វើដំណើរឆ្លងកាត់ទឹកន្លែងភូមិស្រុក ទីនៅទីអា ស្រ័យក៏មិនសូវបាននឹងនរដែរ តែដល់ចាស់វ័យនិងបានបុត្រតំណាង បុត្រមានបុណ្យវាសនា អាចឱ្យពុំនាក់បានជាស្ថាពរ ភរិយាក៏ជាទីពឹងយ៉ាងសំខាន់គ្រប់បែបយ៉ាងប្រចាំជីវិត ។

ខែ តុលា វិច្ឆិកា និង ធ្នូ

មានសម្បត្តិច្រើន បរិបូរទៅដោយលាភយសរឿយៗ ជាមនុស្សមិនបានធ្វើបាបដោយចំណង់ផ្សេងៗ មកលលួង គំនិតពោលពាក្យមានប្រយោជន៍ កិត្តិស័ព្ទល្បីសាយសព្វកន្លែង ទឹកចិត្តស្គាល់ខុសត្រូវ ហើយមានអធ្យាស្រ័យយោគ យល់ល្អ ។

ខែ មករា កុម្ភៈ និង មីនា

មានបញ្ញាច្រើន គំនិតឈ្លាសវៃ ប្រសព្វ ឬកខ្ពស់ កាន់យសសក្តិអំណាចហួសពេក មិនសូវយិតយោងអ្នកណា ឱ្យមានឋានៈថ្លៃថ្នូរ (វណ្ណៈ មច្ឆរិយៈ) ជាមនុស្សលេងឬក លេងខ្លួន ស្រឡាញ់ការសិក្សាជាមធ្យម ចូលចិត្តប្រស់ព្រំកាយដោយគ្រឿងក្រអូប រើសគូស្រករឱ្យសមរម្យសព្វគ្រប់ អារីះបុត្រ ។

## ៤-មនុស្សកើតឆ្នាំថោះ

ខែ មេសា ឧសភា និង មិថុនា

ត្រូវចំណាយគំនិត និងសេចក្តីអង់អាចឱ្យណាស់ ទើបបានរួចខ្លួនជាអ្នកមធ្យម បើបានអប់រំខ្លួនទៅដោយការសិក្សាចំណេះវិជ្ជា ទើបកែខ្លួនបានជាគំនិតបញ្ញា ដែលខ្លួនបានសាងសន្សំមកពីពេលមុន គិតការអ្វីៗលុះត្រាតែ២ដង ទើបបានសំរេចដោយម៉ត់ចត់ ជាមនុស្សជឿទុកចិត្តខ្លួនពេក គំនិតនិងសម្តីមិនសូវស្របផ្លូវគ្នា ។

ខែ កក្កដា សីហា និង កញ្ញា

មានបញ្ញាឃោងអាត្មាបាន សេចក្តីចេះដឹង និងសេចក្តីប្រព្រឹត្តសុទ្ធតែជាគុណប្រយោជន៍ដើម្បីអាត្មា មានវាសនាជីវិតរស់នៅដោយដំណើរមិនស្របតាមគន្លងបិតាមាតា ជាមនុស្សគួរឱ្យកោតសរសើរ សឹងតែសព្វបែបយ៉ាង ការងារធ្វើតែ បង្គួរតែបានផលគ្រប់គ្រាន់ ( មានទឹកដៃ ) ។

ខែ តុលា វិច្ឆិកា និង ធ្នូ

ច្រើនមានជើង ដៃ ប្រកបទៅដោយរោគាពាធចុកចាប់ស្ពឹកស្រពន់ ថ្លក់ គ្រេច សំបូរសេចក្តីកង្វល់ មានចិត្តព្រួយ ជាប់ទោះមានហេតុការណ៍ ឬមិនមានក៏ដោយ សេចក្តីរំខានចិត្តជាការធម្មតារបស់គេ ពេលណាបានសំបូរសប្បាយច្រើនភ្លេចខ្លួនអស់ទាំងទុក្ខព្រួយពីពេលមុន ជីវភាពច្រើនឡើង១ ចុះ១ដូចរលកទឹក ។

ខែ មករា កុម្ភៈ និង មីនា

មានសតិបញ្ញាច្រើន សេចក្តីប៉ិនប្រសប់គ្រប់ផ្លូវ អាចជួយរុញច្រានជីវភាពឱ្យឡើងថ្នាក់ខ្ពស់បាន សម្បជញ្ញៈ រឹង ជំហរល្អ ចាប់ផ្តើមកិច្ចការមានគំនិតខ្ពស់ រក្សាមរតកបានគង់វង្ស មានទីលំនៅប្រាកដប្រជា មារយាទថ្លៃថ្នូរ ។

## ៥-មនុស្សកើតឆ្នាំរោង

ខែ មេសា ឧសភា និង មិថុនា

ជាមនុស្សប្រាសចាកសឹកសត្រូវទាំងពួង មានបរិពារចោមរោមច្រើន សំបូរទៅដោយគ្រឿងប្រើប្រាស់សព្វបែប យ៉ាងបានល្អក្នុងការធ្វើរាជការ ឬកាន់មុខតំណែងសឹងបានមុខនាទីជាធំ មានសេចក្តីរុងរឿង ។

ខែ កក្កដា សីហា និង កញ្ញា

មានការតឹងចង្អៀតក្រៃពេកក្នុងកាលនៅវ័យក្មេង ការបម្រុងជីពបានដោយតក់ក្រហល់ពីខាងដើម ចាប់ផ្តើមការអ្វីដំបូងសុទ្ធតែជួបប្រទះដោយឧបសគ្គ លុះដល់ពេញវ័យសេចក្តីទូលំទូលាយគ្រប់ប្រការ សព្វកិច្ចទាំងអស់មានសេចក្តីចំរើនទៅពេលក្រោយគ្រាឆ្លងផុតពីឧបសគ្គ ។

ខែ តុលា វិច្ឆិកា និង ធ្នូ

ទឹកចិត្តធ្ងន់ធ្ងរចំពោះបច្ចាមិត្តសម្រាប់ខ្លួន សំបូរទៅដោយសេចក្តីអាណិតអាសូរគេទាំងឡាយមិនរើសឋានៈ ច្រើនលះកំណាញ់បរិច្ចាគវត្ថុផ្សេងៗឱ្យដល់អ្នកក្រីក្រ យកចិត្តទុកដាក់ជួយទុក្ខធុរៈដល់អ្នករងគ្រោះទូទៅដោយអើពើក្រៃពេកស្រឡាញ់ការបុណ្យកុសលណាស់ ។

ខែ មករា កុម្ភៈ និង មីនា

បានជាទីស្រឡាញ់នៃអ្នកផងទូទៅ ទាំងរូបសម្បត្តិ ទាំងគុណសម្បត្តិ ធ្វើរាជការស្រឡាញ់មុខការ តែមិនសូវត្រូវជើងចូលគំនិតជាមួយមនុស្សពុករលួយឡើយ ចិតនឹងនរ ទាត់ទ្វេង មិនបានផ្លាស់ប្តូរអាកប្បកិរិយាទៅដោយហេតុអាក្រក់ណាមួយកើតមានចំពោះខ្លួនជាមួយមនុស្សគោរពការងារ ព្រមទាំងគំនិតដែលបានគិតទុកជាមុនក្នុងសភាពថ្លៃថ្នូរ ។

## ៦-មនុស្សកើតឆ្នាំម្សាញ់

ខែ មេសា ឧសភា និង មិថុនា

ទឹកចិត្តខ្ពស់ ហើយរៀបរយល្អ តែសន្ទុះចិត្តរហ័សក្នុងកិច្ចការអ្វីដែលគេបានគិតគូរ រមែងសំរេចដូចគោលដៅមែន ថាបើគេបញ្ចេញសំដីយ៉ាងណា គេខំគោរពពាក្យរបស់គេលុះត្រាតែបានសម្រេចដូចពាក្យគេថាមែនពិត កាលនៅវ័យក្មេង មានទុក្ខលំបាកដោយការគ្រប់គ្រងអាត្មាខុសទំនង លុះដល់ចាស់វ័យបានស្រួលរៀងរហូតដល់អវសាន ។

ខែ កក្កដា សីហា និង កញ្ញា

មានៈរឹងក្លា ចំណាំបានល្អមិនងាយភ្លេច ចិត្តរឹងរុះ ចិត្តរអិល ពោលពាក្យឥតមានសុជីវធម៌ គំនិតច្រើនងប់ងល់ តែ ចិត្តល្អ ត្រូវកលឱ្យគ្មានចេះគិតស្តាយអ្វី សម្បត្តិទ្រព្យមធ្យម ចងកំហឹងទុកបានយូរ ស្រឡាញ់ឆាប់រសាយ ។

ខែ តុលា វិច្ឆិកា និង ធ្នូ

មានអាកប្បកិរិយារៀបរយល្អ មារយាទថ្លៃថ្នូរ ទឹកចិត្តទន់ទោរ សន្តោសច្រើន ជាមនុស្សមានព្យាយាមខ្ជាប់ខ្ជួន មានការអាថិកំបាំងជានិច្ច សំដីនិយាយល្មមប្រមាណ ក្នុងទីប្រជុំមានគេសួរមុនទើបនិយាយ មាឌច្រើនតូច ។

ខែ មករា កុម្ភៈ និង មីនា

បញ្ញាឆ្លាតវៃប្រសប់ក្នុងកិច្ចការប្រកប ព្រមទៅដោយយោបល់ភ្លឺស្វាង ស្រឡាញ់អំពើល្អយ៉ាងផ្តាច់ប្តូរ មានសេចក្តី អង់អាចក្នុងមុខការ ហើយធនធារនិងសេចក្តីលំបាកចំពោះការងារ ប្រាសចាកសត្រូវគ្រប់ប្រភេទ មិនសូវតបនឹងការអា ក្រក់របស់អ្នកដទៃមានមកលើខ្លួន ចិញ្ចឹមអាត្មាតាមការមាន ការបាន ។

## ៧-មនុស្សកើតឆ្នាំមមី

ខែ មេសា ឧសភា និង មិថុនា

មានបញ្ញាជាន់ខ្ពស់ កិច្ចការទាំងពួងរមែងឈ្វេងយល់បានដោយស្មារតីខ្លួនភ្នករព្វកដល់ ចិត្តជាចិត្តត្រជាក់ មានចិត្ត ភក្តីតបុគ្គលគ្រប់ជាន់ថ្នាក់ រក្សាអាត្មាបានជាសុខ អំពើមិនច្របូកច្របល់លាយឡំ ចូលចិត្តតែងប្រាណយ៉ាងហ៊ឺហា ។

ខែ កក្កដា សីហា និង កញ្ញា

គំនិតជ្រុលជ្រួស ឬកពារឱនថយ មារយាទថោក ។ ចំពោះស្ត្រីច្រើនហួសសម្តីបានត្រូវប្រុសព្រមាន ចិត្តជាអ្នក លេង វាយឫកហួសមាឌ កាយវិការច្រើនរលោរលា ចិត្តស្រាល សម្តីធ្ងន់ តែច្រើនជាមនុស្សដើរផ្សងព្រេង ។

ខែ តុលា វិច្ឆិកា និង ធ្នូ

មិនសូវមានសេរីភាពបរិបូរឡើយ បញ្ញាមានច្រើន តែមិនសូវស្រឡាញ់ការសិក្សា បើមានសម្បត្តិហូរហៀយ៉ាង ណាក៏ដោយ ក៏គង់មានមនុស្សចាំថ្កោលទោសជានិច្ច ចៅហ្វាយនាយស្ងួនគ្រងពេញចិត្តណាស់ ធ្វើការរើសឋានៈ ។

ខែ មករា កុម្ភៈ និង មីនា

មានវាសនាល្អ និង បានជាធំ ជាប្រធានលើសបក្ខពួក បញ្ញាភ្លឺស្វាង មានសម្បត្តិស្តុកស្តម្ភ បានរុងរឿងដោយបុណ្យ សក្តិ ចិត្តស្ងួនគ្រងរបស់ទ្រព្យយ៉ាងស្ថិតស្ថេរ តែមិនសូវសំបូរអំណាច ការដើរហើរចប្រ៉ប់អារ៉ាបមិនសូវទៅណាមកណាផ្តេស ផ្តាសទេ ។

## ៨-មនុស្សកើតឆ្នាំមមែ

ខែ មេសា ឧសភា និង មិថុនា

ច្រើនធ្វើដំណើរទៅកាន់ទិសទីផ្សេងៗ វិជ្ជាជីវៈមានល្មមតែបង្គួរ ការប្រកបមុខរបរទៅកាន់ទីឆ្ងាយច្រើនខកខាត ទុនមិនជាទីពេញចិត្ត ពេញអធ្យាស្រ័យញាតិមិត្ត ធ្លាប់ផ្លាស់ចិត្តងាកចេញពីកិច្ចការចាស់អារីះគ្នា ។

ខែ កក្កដា សីហា និង កញ្ញា

ជាមនុស្សសន្សំសេចក្តីទុក្ខព្រួយមកឱបគរលើដើមទ្រូងរឿយៗ គំនិតឆាប់រវាតចេញពីសេចក្តីប្រព្រឹត្ត ឬច្រើនទុញ់តុះនឹងទើសទាល់ មិនសូវបានទៅណាឆ្ងាយដើម្បីកែកំសាន្តដោយចង់ដឹង ចង់ស្គាល់នូវទេសភាពស្រុកភូមិដទៃ សុខប៉ប្រុកនៅតែមួយកន្លែង ។

ខែ តុលា វិច្ឆិកា និង ធ្នូ

ច្រើនឈឺដៃជើង ឬច្រើនប៉ះពារជំពប់ ស្មារតីរឹងប៉ឹងចំណាំបានអង្វែងមិនងាយភ្លេច ឬ ច្រទ្បំ បញ្ញាច្រើនស្រឡាញ់ ការសិក្សាតែខ្សត់ការឧបត្ថម្ភ មានសេចក្តីក្លាហានច្រើន ច្រើនចិត្តដាច់ណាត់ ក្បៀវក្លាសម្តី (រស់តែពាក្យ ត្រចៀកស្លាប់ ឈឹង)។

ខែមករា កុម្ភៈ និង មីនា

មានបុណ្យវាសនាបានជាធំ ដោយសេចក្តីឧបត្ថម្ភពីនាយអភិបាល សម្បត្តិមានស្តុកស្តម្ភ រូបរាងសមរម្យ ស្រឡាញ់សេចក្តីបរិសុទ្ធ ចិត្តធ្ងន់ធ្ងរ អធ្យាស្រ័យមិនមានឥច្ឆាឈ្លានីសគេ បើល្អៗណាស់ អាក្រក់ៗប្រាកដ ត្រូវជើងរួមគំនិតតែជា មួយអ្នកធំតែមិនសូវមានឥទ្ធិពល ។

## ៩-មនុស្សកើតឆ្នាំវក

ខែមេសា ឧសភា និង មិថុនា

ចេះសន្សំសេចក្តីល្អ ដោយយកការទុក្ខលំបាកទៅប្តូរយកថ្នូរល្អ ចិត្តទន់ ត្រជាក់ ច្រើនរកសេចក្តីសប្បាយរីករាយ គំនិតធូរពេកការអ្វីចាប់ផ្តើមដំបូងច្រើនទីសទាស់ បន្ទាប់តទៅបានសម្រេចយ៉ាងប្រណីត ធ្វើការជាឧបការគុណដល់គេមិនបានផលបំណាច់សោះឡើយ បានចំរើនរុងរឿងដោយសេចក្តីប្រព្រឹត្តរបស់ខ្លួន ។

ខែកក្កដា សីហា និង កញ្ញា

មានឥស្សរភាពណាស់ ទ្រព្យសម្បត្តិរកបានយ៉ាងបរិបូរណ៍ តែមិនសូវចេះស្ងួនគ្របទុកដោយដៃឯង ច្រើនបានជាអ្នកធំជាទីពឹងញាតិមិត្តទាំងពួង ទឹកចិត្តចេះយោគយល់ ស្គាល់អធ្យាស្រ័យគេឯង ច្រើនប្រើចិត្តប្រាកដនិយម ។

ខែតុលា វិច្ឆិកា និង ធ្នូ

បញ្ញាមុះមុត សំបូរញាតិព្រៀងលាន ចិត្តធំតែគិតអានល្អ មានបរិពារចោមរោមច្រើន ចូលចិត្តប្រើសេចក្តីរំលោភលើសិទ្ធិអ្នកដទៃ សំបូរទៅដោយសេចក្តីរីករាយ ស្រឡាញ់ទ្រព្យរបស់មិនបានស្ថិតស្ថេរ ប៉ងលើអ្វីច្រើនបានសំរេចដូច បំណង។

ខែមករា កុម្ភៈ និង មីនា

មិនសូវសំបូរមិត្ត រូបកាយច្រើនមិនទាប ច្រើនរស់នៅក្រោមបន្ទុកគ្រួសារ ចូលចិត្តខាងបុណ្យទាន និយាយការអ្វីមិនសូវលាក់លៀម ពាក្យសម្ដីនិយាយដោយក្រែងរអែងខុសត្រូវ ញញើតមុខក្រោយ ឫកពារសុខភាពរាបសារ អធ្យា ស្រ័យមិនរឹងមិនទន់ តែច្រើនសន្ដោសតែខ្លួនឯង ។

## ១០-មនុស្សកើតឆ្នាំរកា

ខែមេសា ឧសភា និង មិថុនា

ចំពោះភេទស្រី រមែងអភ័ព្វប្ដី មានគេឧបត្ថម្ភដើម្បីយកកម្លាំងបម្រើផលប្រយោជន៍ ចិត្តទន់ភ្លន់ ស្រឡាញ់ខ្លួនបានបរិបូរណ៍ដោយគ្រឿងឧបភោគ បរិភោគ គូស្រករច្រើនមានការប្រែសេចក្ដីស្នេហា កាលនៅវ័យក្មេងពេញទៅដោយការលំបាកចិត្ត ។

ខែកក្កដា សីហា និង កញ្ញា

មានភ័ព្វវាសនាល្អ បានជាធំ ជាឥស្សរៈ ចិត្តឆាប់ខឹងឃោរ សំបូរការភ្ញាក់ផ្អើលរសើប ពាក្យសម្ដីពិរោះ សម្លេង ស្អាត មានសតិបញ្ញាច្រើន រស់នៅដោយគំនិតខ្លួន មានបុណ្យសក្ដិ សំបូរទៅដោយសេចក្ដីស្នេហា ។

ខែតុលា វិច្ឆិកា និង ធ្នូ

ច្រើនមានដំណើរទៅកាន់ទិសទីនានា បញ្ញាគ្រោតគ្រាត ច្រើនធ្លាក់គំនិត អស់មានះលង់ខ្លួនទៅក្នុងភាពហានះមានសទ្ធាទន់ជ្រាយ សេចក្ដីព្យាយាមនឹងរលត់បានព្រោះឧបសគ្គ ។

ខែមករា កុម្ភៈ និង មីនា

មានកម្លាំងព្យាយាម អង់អាច គំនិងដៅចំពោះជោគជតាវាសនាខ្ពស់ថ្កើង ចេះសន្សំទ្រព្យមានសម្បត្តិច្រើន បញ្ញា ជ្រាលជ្រៅ មានវិជ្ជាជីវៈប្រចាំការ សេចក្ដីចេះដឹងមានផលប្រយោជន៍ល្អ ប្រកាន់ខ្លួនពេកជាហេតុនាំឱ្យឆាប់បែកសាមគ្គីមិត្ត

## ១១-មនុស្សកើតឆ្នាំច

ខែមេសា ឧសភា និង មិថុនា

ជាមនុស្សមានចិត្តកង្វល់ ដោយមានគេហាមឃាត់ផ្សេងៗ ក្នុងកាលខ្លួននៅវ័យក្មេង ចិត្តធំ គំនិតឆ្និនល្អ ត្រូវគេលួងលោមបញ្ចុកបញ្ចើ លុះដល់វ័យពេញលក្ខណៈបានល្អ ដោយមានគេជួយយិតយោងណែនាំឱ្យដើរទៅកាន់វឌ្ឍនភាព ។

ខែកក្កដា សីហា និង កញ្ញា

បញ្ញាល្អិតសុខុម ស្មារតីមាំមួនល្អ ចូលចិត្តស្វែងរកផលប្រយោជន៍ មានបុណ្យវាសនារក្សាវង្សត្រកូល ។

ខែតុលា វិច្ឆិកា និង ធ្នូ

ចិត្តកាចកោង សំបូរបរិពារចោមរោម ទិដ្ឋិរឹងថ្មឹង មានមានះ ក្លាហាន ស្រឡាញ់ពូជអំបូរញាតិមិត្តយ៉ាងប្តូរផ្តាច់សងគំនុំនៅក្នុងទិចំពោះមុខ ត្រូវការសេចក្ដីសប្បាយច្រើនណាស់ ។

ខែមករា កុម្ភៈ និង មីនា

សំបូរទៅដោយគ្រឿងឧបភោគ និងបរិភោគ មានទ្រព្យបរិបូរណ៍ ថ្វីមាត់សំខាន់ ចិត្តក្លាហាន កាយច្រើនធំធាត់ងាយក្នុងការប្រកបអាជីវកម្ម ចូលចិត្តធ្វើការច្រើន ។

## ១២-មនុស្សកើតឆ្នាំកុរ

ខែមេសា ឧសភា និង មិថុនា

គំនិតដែលបានគិតច្រើនត្រូវ ច្រើនប្រកប សំបូរសប្បាយច្រើន ជាទីពេញចិត្តរាប់រកយកជាគ្នានៃផងទូទៅ មាន ភ័ព្វល្អ វាសនាខ្ពស់ មានអ្នកធំជួយស្រោចស្រង់ផ្គុងផ្តើម ។

ខែកក្កដា សីហា និង កញ្ញា

ច្រើនខ្ជិលច្រអូសប្រចាំចិត្តបន្តិច មានបុណ្យសក្តិ ចិត្តស្មោះត្រង់តមិត្ត ឬអ្នកដទៃ បញ្ញាយឺតយ៉ាវ ច្រើនលុះគំនិតតាមសម្តីគេពោលនាំមុខ ចិត្តល្អចំពោះគេ គេប៉ងអាក្រក់តបវិញ ជួយទុក្ខធុរៈអ្នកណាគ្មានសំចៃកម្លាំង ។

ខែតុលា វិច្ឆិកា និង ធ្នូ

ចិត្តធ្ងន់ធ្ងរ មានសេចក្តីធន់ស៊ូណាស់ ច្រើនស្រឡាញ់បញ្ចើចលើកជើងពីអ្នកដទៃ និយាយពាក្យសាំឡាំរោយរាយ ហើយច្រើនរអ៊ូរទាំផង ច្រើនពោលច្រំដែលៗបន្តិច រូបរាងកាយច្រើនមានបូសកមរមាស់ ច្រើនត្រូវបានគេពេបជ្រាយឱ្យពី ក្រោយខ្នង ទោះជួយឈឺឆ្អាលគេយ៉ាងណាក៏ដោយ ។

ខែមករា កុម្ភៈ និង មីនា

មានគំនិតឆ្និនប៉ិនប្រសប់ខាងការត្រិះរិះពិចារណា (តកវិជ្ជា)សំដីមានហេតុផលល្អ ចិត្តស្រឡាញ់ខាងផ្លូវកុសល សីល ទាន ឈ្វេងយល់បានដោយងាយនូវកិច្ចកលសព្វយ៉ាង បញ្ញាឆ្លាតវៃស្វាតតីនឹងនរ ចូលចិត្តកាច់រង្គាត់មើលទេសភាព ផ្សេងៗ ហ៊ានបានហ៊ានបង់ណាស់ ចេះរក្សាក្រុមពួក ។